# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអគ្គសញ្ញាអាពាហ៍ពិពាហ៍នៅព្រះសហគមន៍សន្តីម៉ារីញញឹម
# ចំការទៀង ថ្ងៃទី១១ ខែមករា ឆ្នាំ២០២០
# គោលដៅនៃការបង្កើតគ្រួសារដ៏សុខសាន្ត

**អត្ថបទទី១៖ កំណើតពិភពលោក ២,១៨.២១-២៤**

ព្រះជាអម្ចាស់មានព្រះបន្ទូលថា៖ «បើមនុស្សប្រុសនៅតែឯងដូច្នេះមិនស្រួលទេ យើងនឹងបង្កើតម្នាក់ទៀតឲ្យជួយ និងបានជាគ្នា»។ កណ២,១៨

**ដំណឹងល្អ៖ យ៉ូហាន ២,១-១០**

មាតារបស់ព្រះអង្គប្រាប់ទៅពួកអ្នកបម្រើថា៖ «បើលោកប្រាប់ឲ្យធ្វើអ្វី ចូរធ្វើតាមទៅ»។ យហ ២,៥

បងប្អូនជាទីស្រឡាញ់!

សេចក្ដីសុខនិងអំណរសប្បាយ ជាគោលដៅនៃជីវិតយើង ព្រះយេស៊ូនៅពេលចាប់ផ្ដើមបេសកកម្មរបស់ព្រះអង្គ ព្រះអង្គបានចូលរួមនៅក្នុងពិធីមង្គលការដើម្បីចូលនៅក្នុងអំណរសប្បាយរបស់ប្រជាជន។ ថ្ងៃនោះ ខ្វះស្រាសម្រាប់ទទួលភ្ញៀវ ព្រះយេស៊ូបានធ្វើសញ្ញាមួយប្លែកដោយធ្វើឲ្យទឹកក្លាយទៅជាស្រាទំពាំងបាយជូរ។ ហេតុនេះហើយ យើងអាចយល់ថានៅក្នុងជីវិតរបស់យើង អំណរសប្បាយនិងសេចក្ដីសុខជាគោលដៅសំខាន់ណាស់។ ប៉ុន្តែ ពិភពលោករបស់យើងខ្វះសេចក្ដីសុខនិងអំណរសប្បាយ ព្រះជាម្ចាស់បានបង្កើតបុរសនិងស្ត្រីធ្វើជាប្ដីប្រពន្ធដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត។ ពេលមានគូស្រករថ្មី យើងអធិដ្ឋានសម្រាប់ទាំងពីរនាក់ឲ្យមានសេចក្ដីសុខអស់មួយជីវិត ដោយបង្កើតគ្រួសារដ៏សុខសាន្ត។

នៅពេលខ្ញុំទៅមន្ទីរឃុំឃាំង នៅពេលខ្ញុំបានឃើញកូនពិការចូលលេងនៅក្នុងទឹកសមុទ្រ ខ្ញុំបានគិតអំពីតម្លៃនៃសេរីភាព។ អ្នកជាប់ក្នុងមន្ទីរឃុំឃាំងគេមិនមានសេរីភាពមែន តែគេបានត្រៀមខ្លួនស្គាល់សេរីភាពសាជាថ្មីនៅពេលគេចេញពីទីនោះ។ កូនក្មេងពិការជួនកាលអត់សូវមានសេរីភាពដែរ ដោយសារគេមិនអាចធ្វើអ្វីដែលគេចង់ធ្វើ ប៉ុន្តែនៅពេលគេចូលនៅក្នុងទឹកសមុទ្រឃើញថាគេមានស្នាមញញឹមស្អាតណាស់ គេពោរពេញដោយសេរីភាព គេអាចធ្វើកាយវិការខ្លះៗ។ សេរីភាពសំខាន់ណាស់ ប្រជាជនខ្មែរបានរកឃើញសេរីភាពវិញនៅថ្ងៃទី០៧ ខែមករា ឆ្នាំ ១៩៧៩ មុនគេបង្អស់ប្រជាជនគាត់បានធ្វើដំណើរទៅភូមិកំណើត ដើម្បីជួបជុំក្រុមគ្រួសារសាជាថ្មីដែលបែកបាក់គ្នាជាង៣ឆ្នាំក្នុងសម័យដ៏ខ្មៅងងឹត។ យើងបានកសាងគ្រួសាររបស់យើងសាជាថ្មីដោយសារគ្រួសារជាមូលដ្ឋានដ៏សំខាន់បំផុតនៅក្នុងជីវិត ក្រោយមកគេធ្វើស្រែដើម្បីចិញ្ចឹមជីវិត។

គ្រួសារមានសេចក្តីសុខ នៅពេលយើងមានការងារធ្វើដើម្បីចិញ្ចឹមជីវិតផ្ទាល់ខ្លួន និងមានសេរីភាពនៅក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិដែលយើងរកបាន។ យើងមានសមត្ថភាព ដើម្បីបញ្ជូនកូនៗទៅសាលារៀន ដើម្បីឲ្យកូនរៀនសូត្រ និងទទួលតម្លៃនៃជីវិត គុណធម៌ សីលធម៌ នៅក្នុងខ្លួន។ មនុស្សយើងត្រូវតែមានសាសនា នេះជាអាពាហ៍ពិពាហ៍អន្តរសាសនា ប្តីជាគ្រីស្តបរិស័ទ ប្រពន្ធជាពុទ្ធបរិស័ទ ជីវិតរបស់យើងទទួលព្រះពរពីសាសនាដើម្បីរួមរស់នៅក្នុងសេចក្តីសុខ។ គ្រួសារដ៏សុខសាន្ត ជាគ្រួសារដែលសមាជិកម្នាក់ៗចេះស្រឡាញ់គ្នាទៅវិញទៅមក គ្មានសេចក្តីស្រឡាញ់គ្រួសារគ្មានសេចក្តីសុខទេ។ នេះសំខាន់ណាស់ ចិញ្ចឹមជីវិត អប់រំកូន គោរពសាសនា និងរស់នៅក្នុងសេចក្តីស្រឡាញ់ ដោយចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។

យើងអធិដ្ឋាន ដើម្បីឲ្យគូស្រករថ្មីនេះបង្កើតគ្រួសារដ៏សុខសាន្ត ដែលចេះស្រឡាញ់ ដែលមានចិត្តបម្រើ ឲ្យយើងទៅជាគ្រួសារដែលចេះមើលសេចក្តីត្រូវការរបស់បងប្អូនឯទៀតៗ។ អាម៉ែន៕